N.2
15.01.02

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-  ព្រះរាជក្រម

០៧-០១-២០០២ -ព្រះរាជក្រម នស/រកម/០១០២/០០១ ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ៦៤

០៧-០១-២០០២ -ព្រះរាជក្រម នស/រកម/០១០២/០០២ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ៧៥

០៧-០១-២០០២ -ព្រះរាជក្រម នស/រកម/០១០២/០០៣ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៩ របស់អាស៊ានស្តីពីកាតព្វកិច្ចធានារ៉ាប់រងយានយន្ត ៧៧

០៧-០១-២០០២ -ព្រះរាជក្រម នស/រកម/០១០២/០០៤ ច្បាប់ស្តីពី ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ៧៩

០៧-០១-២០០២ -ព្រះរាជក្រម នស/រកម/០១០២/០០៥ ច្បាប់ស្តីពី វិសោធនកម្មមាត្រា ៣៦ មាត្រា ៣៨ មាត្រា ៩០ និង មាត្រា ៩១ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ៨៤ក

### ២-ព្រះរាជក្រឹត្យ

០៣-០១-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០១០២/០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌ មន្ត្រីរាជកាចការបរទេស ៨៥

០៣-០១-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០១០២/០០២ ស្តីពីការតែងតាំងឯកឧត្តម **ជ័យ សាផុន** ជាសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ៩២

១០-០១-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០១០២/០០៦ ស្តីពីការតំឡើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយឯក ជាកិច្ចបច្ឆាមរណៈចំពោះសពឧត្តមសេនីយ៍ទោ **ផា ថនចាន់** ៩៤

១០-០១-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០១០២/០០៧ ស្តីពីការប្រោសព្រះរាជទាន ចំពោះឯកឧត្តម **សោម ចិន** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា**ថ្នាក់**សេនា** ៩៥

១៤-០១-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០១០២/០០៨ ស្តីពីការតំឡើងឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈចំពោះ សព វរសេនីយ៍ឯកសេនីយ៍ឯក **សុខ វាសនា** ៩៦

១៤-០១-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០១០២/០០៩ ស្តីពីការតែងតាំងឥស្សរជន ០៣ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាមានឋានៈស្មើអនុរដ្ឋលេខាធិការ ដូចមានរាយនាមខាងក្រោម : ៩៧

១៤-០១-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០១០២/០១០ ស្តីពីការបំពាក់គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **មហាសេរីវឌ្ឍន៍** ជូនលោកឧកញ៉ា **ម៉ុង ឫទ្ធី** ៩៨

១៤-០១-២០០២ -ព្រះរាជក្រឹត្យ នស/រកម/០១០២/០១១ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជា

| | | |
|---|---|---|
| | តូបនីយកម្មដល់លោក **ឈិន រ៉ុនមិញ** (CHEN RON-MING)ហៅ **តាំង ឡុងមិញ** (TANG LONG MING) សញ្ជាតិដើមចិន | ៩៩ |


## II- រាជរដ្ឋាភិបាល

### ១_ អនុក្រឹត្យ


| | | |
|---|---|---|
| ០៩-០១-២០០២ | អនុក្រឹត្យលេខ ១២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១០០ |
| ០៩-០១-២០០២ | អនុក្រឹត្យលេខ ១៤ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខងារនាយនគរបាលជាតិ | ១០២ |
| ១៤-០១-២០០២ | អនុក្រឹត្យលេខ ១៣ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១០៣ |
| ១៤-០១-២០០២ | អនុក្រឹត្យលេខ ១៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១០៧ |
| ១៥-០១-២០០២ | អនុក្រឹត្យលេខ ១៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១០៨ |
| ១៥-០១-២០០២ | អនុក្រឹត្យលេខ ១៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១១២ |
| ១៥-០១-២០០២ | អនុក្រឹត្យលេខ ១៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ១២០ |


### ២_សេចក្តីសំរេច


| | | |
|---|---|---|
| ១០-០១-២០០២ | សេចក្តីសំរេចលេខ ០០១ សសរ. ស្តីពីការបង្កើតគណៈកម្មការកិច្ចប្រជុំរដ្ឋមន្ត្រីអភិវឌ្ឍន៍ជនបទ និងលុបបំបាត់ភាពក្រីក្រអាស៊ាន | ១២១ |


### ៣_សេចក្តីណែនាំ


| | | |
|---|---|---|
| ១០-០១-២០០២ | សេចក្តីណែនាំលេខ ០១ សណន. ស្តីពីការសុំច្បាប់ឈប់ពិសេសរបស់មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ ដែលជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ | ១២៣ |
| ១៥-០១-២០០២ | សេចក្តីណែនាំលេខ ០២ សណន. ស្តីពីការដាក់ឱ្យអនុវត្តន៍ ការប្រើប្រាស់អត្តសញ្ញាណប័ណ្ណ មន្ត្រីរាជការស៊ីវិល ថ្នាក់ខេត្ត-ក្រុង | ១២៤ |


### ៤_សេចក្តីថ្លែងការណ៍


| | | |
|---|---|---|
| ១៤-០១-២០០២ | សេចក្តីថ្លែងការណ៍លេខ ០១ សអន. របស់រាជរដ្ឋាភិបាល | ១២៧ |


## III- ការងារបណ្តាក្រសួង

### ទីស្តីការរដ្ឋមន្ត្រីក្រសួង ធម្មការ និងសាសនា


| | | |
|---|---|---|
| ០៩-០១-២០០២ | សេចក្តីសំរេចលេខ ០៥ កធ.សសរ. ស្តីពីការអនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តឈ្មោះ " សេវេនដេយអាត់វេនទីស្ទ " មួយកន្លែងដែលមានទីតាំងនៅភូមិចំបក់ ឃុំអូរស្ពានមានជ័យ ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគីរី | ១៣០ |
| ០៩-០១-២០០២ | សេចក្តីសំរេចលេខ ០៦ កធ.សសរ. ស្តីពីការអនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តឈ្មោះ " សន្ទះអង់កូនឆ្នុកទ្រូ " មួយកន្លែងដែលមានទីតាំងនៅភូមិឆ្នុកទ្រូ ឃុំឆ្នុកទ្រូ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង | ១៣២ |

2.02

# ព្រះរាជក្រម

នស/រកម/០១០២/០០១

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល-កម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី ៦ នីតិកាលទី ១ ហើយដែលមាន សេចក្តីទាំងស្រុង ដូចតទៅ :

# ច្បាប់
# ស្តីពី
# ការទូទាត់ថវិកាទូទៅរបស់រដ្ឋ
# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានយល់ព្រមតាមការអនុវត្តន៍នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥, ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ។ ការអនុវត្តន៍នេះ លេចចេញជាលទ្ធផល ដូចមានចែងក្នុងតារាងសរុបខាងក្រោមនេះ ÷

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការចំណូល ចំណាយនៃការគ្រប់គ្រង ឆ្នាំ ២០០០ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ ២០០០ | ច្បាប់ទូទាត់ថវិកាឆ្នាំ ២០០០ |
|---|---|---|
| សរុបចំណូល[(១)] | ២.៣៥៥.០០០ | ២.០៥៦.៥៧៦ |
| សរុបចំណាយ | ២.៣៥៥.០០០ | ២.០៩៩.៩៧៤ |
| ចំនួនអតិរេកនៃគណនេយ្យចំណូល/ចំណាយ | - | + ៧.០៩៩ |
| កិច្ចប្រតិបត្តិការនៃច្បាប់ហិរញ្ញវត្ថុដែលបានអនុវត្តដោយរតនាគារជាតិ | | |
| ចំណូលថវិកា | ១.៦៥៥.០០០ | ១.៥៣៥.៧៩៩ |
| • ចំណូលជាប្រចាំ | ១.៤៨៥.០០០ | ១.៣៩៣.៩៩៩ |
| • ចំណូលជាមូលធនក្នុងប្រទេស | ២០.០០០ | ២៩.៨២២ |
| • ចំណូលជាមូលធនក្រៅប្រទេស | ១៥០.០០០ | ១១២.៩៧៨ |
| ចំណាយថវិកា | ១.៦៥៥.០០០ | ១.៥២៨.៧០០ |
| • ចំណាយជាប្រចាំ | ១.៣១៥.០០០ | ១.២១៥.៤៧៧ |
| • ចំណាយជាមូលធន | ៣៤០.០០០ | ៣១៣.២២៣ |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទាន ក្រៅប្រទេសផ្ទាល់ ដែលបានអនុវត្តក្រៅរតនាគារជាតិ | | |
| • ធនធានជាមូលធន សំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៧០០.០០០ | ៥២០.៩៧៨ |
| • ចំណាយជាមូលធនដោយធនធាន សំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៧០០.០០០ | ៥២០.៩៧៨ |

(១) ក្នុងនោះមានវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលបានលើកឡើងនេះ គ្រាន់តែជាការចង្អុលបង្ហាញប៉ុណ្ណោះ ពីព្រោះកិច្ចប្រតិបត្តិការដែលបានអនុវត្តផ្ទាល់ដោយហិរញ្ញប្បទានក្រៅប្រទេស មិនឆ្លងកាត់រតនាគារជាតិ និង មិនបានចុះកិច្ចបញ្ជីការគណនេយ្យក្នុងលេខនាររតនាគារជាតិទេ កិច្ចប្រតិបត្តិការនេះគឺគ្រាន់តែជាការប៉ាន់ប្រមាណ ដោយមានទំនាក់ទំនងផ្ទាល់ជាមួយអ្នកផ្តល់មូលនិធិ ។

មាត្រា ២.-

ចំណូលថវិកា ដែលបានអនុវត្តដោយរតនាគារជាតិ ត្រូវបានលំអិតតាមមាតិកា នៅក្នុងតារាង "ក" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

ចំណាយថវិកា ដែលបានអនុវត្តដោយរតនាគារជាតិ ក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០០ ត្រូវបានលំអិតតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែល និង តាមជំពូកនៅក្នុងតារាង "ខ" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

តារាង "ខ១" ដែលភ្ជាប់មកជាមួយច្បាប់នេះ គឺជាបញ្ជីនៃគំរោងវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្នុងប្រទេស ដែលបានសំរេចក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០០ និងដែលបានបែងចែកតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែល ។

ការប៉ាន់ប្រមាណសំរេចបាន ស្តីពីវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០០ ចំពោះចំណូលត្រូវបានលំអិតតាមមាតិកាថវិកា និង ចំពោះចំណាយត្រូវបានលំអិតតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែល ហើយត្រូវបានបញ្ជាក់ជាបន្តបន្ទាប់នៅក្នុងតារាង "ក" និង "ខ" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

តារាង "ខ២" ដែលភ្ជាប់មកជាមួយច្បាប់នេះ គឺជាបញ្ជីនៃគំរោងវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ក្រៅរតនាគារជាតិ ដែលបានសំរេចក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០០ នឹងត្រូវបានបែងចែកតាមក្រសួង និង ស្ថាបន័សាធារណៈប្រហាក់ប្រហែលដោយអ្នកផ្តល់បរទេស ។

# ជំពូកទី ២

## បទប្បញ្ញត្តិ

## ស្តីពីកិច្ចប្រតិបត្តិការថវិកា

មាត្រា ៣.-

ការប្រមូលចំណូល ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋពីពន្ធដារ វិភាគទាន អាករ ផលិតផល និង ផលទុន ព្រមទាំងការសំរេចបាននូវអំណោយ មូលនិធិបដិភាគ និង ធនធានដែលបានមកពីការខ្ចី ដែលមានចែង នៅក្នុងច្បាប់

ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ មានចំនួនទឹកប្រាក់សរុប............................ ...................................................................................................... ១.៦៥៥.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់................................ ១.៥៣៥.៧៩៨ លានរៀល

ដូច្នេះមានចំណូលខ្វះចំនួន........................................ (-) ១១៩.២០២ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តន៍ដូចតទៅ ÷

ចំណូលចរន្ត - គំរោង.................... ១.៤៨៥.០០០ លានរៀល

- ការសំរេចបាន... ១.៣៩៣.៤៩៨ លានរៀល

- មានចំនួនខ្វះ......... (-)៩១.៥០២ លានរៀល

ចំណូលជាមូលធនក្នុងប្រទេស - គំរោង.............................. ២០.០០០ លានរៀល

- ការសំរេចបាន........... ២៩.៣២២ លានរៀល

- មានចំនួនលើស.... (+)៩.៣២២ លានរៀល

ចំណូលជាមូលធនក្រៅប្រទេស- គំរោង........................ ១៥០.០០០ លានរៀល

- ការសំរេចបាន......... ១១២.៩៧៨ លានរៀល

- មានចំនួនខ្វះ...... (-)៣៧.០២២ លានរៀល

មាត្រា ៤.~

ចំណាយថវិកាទូទៅរបស់រដ្ឋ ដែលមានចែងនៅក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ មានចំនួនទឹកប្រាក់សរុប.............. ១.៦៥៥.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់................................ ១.៥២៨.៧០០ លានរៀល

ដូច្នេះមានចំណាយខ្វះឥណទានថវិកាចំនួន............ (-)១២៦.៣០០ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តន៍ដូចតទៅ ÷

ចំណាយចរន្ត - គំរោង.................. ១.៣១៥.០០០ លានរៀល

- ការសំរេចបាន... ១.២១៥.៤៧៧ លានរៀល

- មានចំនួនខ្វះ....... (-)៩៩.៥២៣ លានរៀល

ចំណាយជាមូលធននៃវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ÷

- គំរោង........................ ៣២០.០០០ លានរៀល

- ការសំរេចបាន........ ៣០៣.៤០៩ លានរៀល

- មានចំនួនខ្វះ.......... (-)១៦.៥៩១ លានរៀល

ចំណាយជាមូលធននៃការវិលសំបំណុល ÷

- គំរោង............................២០.០០០ លានរៀល
- ការសំរេចបាន.................៩.៨១៤ លានរៀល
- មានចំនួនខ្វះ.........(-)១០.១៨៦ លានរៀល

**មាត្រា ៥.-**

ការអនុវត្តន៏កិច្ចប្រតិបត្តិការចំណូល និង ចំណាយតាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលបានសំរេចដោយរតនាគារជាតិ ដូចមានចែងនៅក្នុងមាត្រា៣ និង មាត្រា៤ នៃច្បាប់នេះ បានបង្ហាញជាលទ្ធផលនូវអតិរេកគណនេយ្យនៃចំណូល និង ចំណាយដូចតទៅ ÷

- ចំណូលថវិកាដែលបានសំរេចដោយរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ មានចំនួន............................................................................១.៥៣៥.៧៩៨ លានរៀល
- ចំណាយថវិកាដែលបានសំរេចដោយរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ មានចំនួន............................................................................១.៥២៨.៧០០ លានរៀល
- អតិរេកគណនេយ្យពិតនៃចំណូលនិងចំណាយ.........(+)៧.០៩៨ លានរៀល

អតិរេកគណនេយ្យនេះ គឺជាលទ្ធផលនៃ ÷

- អតិរេកនៃចំណូល និង ចំណាយចរន្ត.............(+)១៧៨.០២១ លានរៀល
- និងឱនភាពនៅក្នុងកិច្ចប្រតិបត្តិការជាមូលធន (-)១៧០.៩២៣ លានរៀល

ដោយអនុលោមទៅតាមបទប្បញ្ញត្តិក្នុងមាត្រា ៥៧ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស.៩៣, ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ អតិរេកគណនេយ្យនៃចំណូល និង ចំណាយសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ មានចំនួនទឹកប្រាក់ (+)៧.០៩៨ លានរៀល ត្រូវបានកត់ត្រានៅក្នុងគណនីលទ្ធផល ដែលបានបើកនៅក្នុងលេខានៃរតនាគារជាតិ ។

# ជំពូកទី ៣

## បទប្បញ្ញត្តិស្តីពីវិនិយោគសាធារណៈដោយហិរញ្ញប្បទាន ក្រៅប្រទេសផ្ទាល់ដែលបានអនុវត្តក្រៅរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០

មាត្រា ៦.-

វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលបានអនុវត្តក្រៅរតនាគារជាតិ និង ដែលបានគ្រោងទុកសរុបចំណូលស្មើនឹងសរុបចំណាយសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ មានចំនួនទឹកប្រាក់................ ៧០០.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់........................................ ៥២០.៧៧៨ លានរៀល

ដូច្នេះមានចំនួនខ្វះ........................................................ (-)១៧៩.២២២ លានរៀល ។

# ជំពូកទី ៤

## បទប្បញ្ញត្តិស្តីពី តុល្យភាពហិរញ្ញវត្ថុសាធារណៈសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០

មាត្រា ៧.-

តុល្យភាពហិរញ្ញវត្ថុសាធារណៈជាស្ថាពរ នៃថវិកាទូទៅរបស់រដ្ឋបានបង្ហាញនូវប្រភេទនៃកិច្ចប្រតិបត្តិការ ដូចតទៅ ÷

- កិច្ចប្រតិបត្តិការថវិកា : តារាង “ក”: ចំណូលថវិកាទូទៅរបស់រដ្ឋ និង តារាង “ខ” : ចំណាយថវិកាទូទៅរបស់រដ្ឋ ។
- កិច្ចប្រតិបត្តិកានៃរតនាគារជាតិ ។
- ទំនាក់ទំនងហិរញ្ញវត្ថុរបស់រដ្ឋជាមួយនឹងធនាគារជាតិនៃកម្ពុជា ។

តុល្យភាពហិរញ្ញវត្ថុដែលសំរេចបានជាស្ថាពរ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ បានឆ្លុះបញ្ចាំងនៅក្នុងតារាងនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ ដូចខាងក្រោម ÷

ឯកតា: លានរៀល

| តារាងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ | ចំនួនទឹកប្រាក់ | ចំនួនលើស(+).ឱនភាព(-) |
|---|---|---|
| I - ចំណូលក្នុងប្រទេស | ១.៤២២.៨២០ | |
| ១ - ចំណូលជាប្រចាំក្នុងប្រទេស | ១.៣៩៣.៤៩៨ | |
| ២ - ចំណូលជាមូលធនក្នុងប្រទេស (ឯកជនភាវូបនីយកម្ម) | ២៩.៣២២ | |
| II - ចំណាយថវិកា | ២.០៣៩.៦៦៤ | |
| ១ - ចំណាយជាប្រចាំ | ១.២១៥.៤៧៧ | |
| ២ - ចំណាយជាមូលធន[២] | ៨២៤.១៨៧ | |
| ក្នុងនោះ ÷ | | |
| * វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ៣០៣.៤០៩ | |
| - ដោយមូលនិធិថវិកា | ៣០១.៦១៣ | |
| • គំរោងវិនិយោគ (សាងសង់, ទព្វសម្ភារៈ) | ២២០.៦១៥ | |
| • បដិភាគរួមចំណែកជាមួយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៨០.៩៩៨ | |
| - ដោយមូលនិធិក្រៅប្រទេសដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ | ១.៧៩៦ | |
| * វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់(ជំនួយគំរោងការ) | ៥២០.៧៧៨ | |
| អតិរេកនៃថវិកាជាប្រចាំ (តាមនិយមន័យសន្សាផ្តល់) | | (+)១៧៨.០២០ |
| ឱនភាពនៃថវិកាទូទៅ (តាមនិយមន័យសន្សាផ្តល់) | | (-)៦១៦.៨៤៥ |
| III - កំណែតំរូវ | | (+)១០.១៤៥[៣] |
| អតិរេកនៃថវិកាជាប្រចាំ (តាមនិយមន័យបេឡា) | | (+)១៨៨.១៦៥ |
| ឱនភាពនៃថវិកាទូទៅ (តាមនិយមន័យបេឡា) | | (-)៦០៦.៧០០ |
| IV - ហិរញ្ញប្បទាននៃឱនភាព | | (+) ៦០៦.៧០០ |
| ១ - ហិរញ្ញប្បទានក្រៅប្រទេស | | (+) ៦៣៥.៦៦១ |
| • ជំនួយទ្រទ្រង់ថវិកាមិនមានកំណត់មុខសញ្ញាចំណាយ | | 0 |
| • ជំនួយទ្រទ្រង់ថវិកាដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ | | (+) ១១២.៩៧៨ |
| • ជំនួយគំរោងការ | | ៥២២.៦៨៣[៤] |
| ២ - ការរំលស់បំណុលបរទេស | | 0 |
| ៣ - ហិរញ្ញប្បទានក្នុងប្រទេស | | (-) ១៩.៤៥២ |
| • ហិរញ្ញប្បទានធនាគារ | | (-) ១១៤.៥៥៧ |
| ក្នុងនោះ - ខ្ចីពីធនាគារ | | (-) ៦.១៩២ |
| - ការរំលស់បំណុលក្នុងប្រទេស | | (-) ៣.៦២២ |
| • ប្រាក់បញ្ញើផ្សេងៗទៀតនៃរតនាគារ | | (+) ៩៥.១០៥ |
| ៤ - កិច្ចប្រតិបត្តិការកំពុងដំណើរការ | | (-) ៩.៥០៩ |

(២) មិនបានគិតការរំលស់បំណុល ៩.៨១៤ លានរៀលទេ ។

(៣) បំរែបំរួលសុទ្ធនៃអាណត្តិបើកប្រាក់ដែលមានសល់មិនទាន់បានបើកផ្តល់នៅរតនាគារ និង បុរេប្រទានត្រូវធ្វើនិយ័តភាវូបនីយកម្ម ។

(៤) ក្នុងនោះមានទឹកប្រាក់ចំនួន ១.៩០៥ លានរៀល ដែលត្រូវវង់ចាំការប្រើប្រាស់ ។

# ជំពូកទី ៥

# បទបញ្ញត្តិស្តីពី

# ការទូទាត់ថវិការបស់ខេត្ត ក្រុង

# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០

មាត្រា ៨.-

ដោយអនុលោមតាមបទប្បញ្ញត្តិ មាត្រា ១៨ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស.រកម.០២៩៨.០៣, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ និងមាត្រា ១៦ នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥, ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៩ ត្រូវបានយល់ព្រមតាមការអនុវត្តន៍ នូវកិច្ចប្រតិបត្តិការចំណូល និង ចំណាយថវិការបស់ខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលលេចចេញជាលទ្ធផលដូចបានបង្ហាញនៅក្នុងតារាងខាងក្រោមនេះ ÷

ឯកតា: រៀល

| កិច្ចប្រតិបត្តិការចំណូល និង ចំណាយថវិកា របស់ខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ | ច្បាប់ហិរញ្ញវត្ថុ ដើមឆ្នាំ ២០០០ | ច្បាប់ទូទាត់ថវិកា ខេត្ត ក្រុងឆ្នាំ ២០០០ | លើស(+) ខ្វះ (-) |
|---|---|---|---|
| សរុបចំណូល | ៤៤.០០០.០០០.០០០ | ៥៧.៨៨៤.៨០៨.៧៨៨ | +១៣.៨៨៤.៨០៨.៧៨៨ |
| សរុបចំណាយ | ៤៤.០០០.០០០.០០០ | ៥៣.៥៣២.៥៦៥.៨៤៤ | +៩.៥៣២.៥៦៥.៨៤៤ |
| អតិរេកគណនេយ្យនៃចំណូល និង ចំណាយ | | ៤.៣៥២.២៤២.៩៤៤ | +៤.៣៥២.២៤២.៩៤៤ |
| កិច្ចប្រតិបត្តិការនៃថវិការបស់ខេត្ត ក្រុង | | | |
| I. ចំណូលថវិកា | ៤៤.០០០.០០០.០០០ | ៥៧.៨៨៤.៨០៨.៧៨៨ | +១៣.៨៨៤.៨០៨.៧៨៨ |
| - ចំណូលជាប្រចាំ | ៤៤.០០០.០០០.០០០ | ៥៥.៧៤៩.០១១.៧៨៨ | +១១.៧៤៩.០១១.៧៨៨ |
| • ចំណូលសារពើពន្ធ | ១៧.៨០០.០០០.០០០ | ២៨.៨៩១.៨៤០.៣០៨ | +១១.០៩១.៨៤០.៣០៨ |
| • ចំណូលពុំមែនសារពើពន្ធ | ៦.២០០.០០០.០០០ | ៦.៩១៦.១៧១.៤៨០ | +៧១៦.១៧១.៤៨០ |
| • ឧបត្ថម្ភពីថវិការដ្ឋ | ២០.០០០.០០០.០០០ | ១៩.៩៤១.០០០.០០០ | -៥៩.០០០.០០០ |
| - ចំណូលជាមូលធន | 0 | ២.១៣៥.៧៩៧.០០០ | +២.១៣៥.៧៩៧.០០០ |
| • ចំណូលជាមូលធនផ្ទៃក្នុង | 0 | ១៣៧.០០០ | +១៣៧.០០០ |
| • ចំណូលជាមូលធននៃវិនិយោគដោយថវិការដ្ឋ (កម្មវិធីសិលា) | 0 | ២.១៣៥.៦៦០.០០០ | +២.១៣៥.៦៦០.០០០ |
| II. ចំណាយថវិកា | ៤៤.០០០.០០០.០០០ | ៥៣.៥៣២.៥៦៥.៨៤៤ | +៩.៥៣២.៥៦៥.៨៤៤ |
| - ចំណាយជាប្រចាំ | ៤៤.០០០.០០០.០០០ | ៥១.៣៩៨.៥៤៦.៧៤៤ | +៧.៣៩៨.៥៤៦.៧៤៤ |
| - ចំណាយជាមូលធន | 0 | ២.១៣៤.០១៩.១០០ | +២.១៣៤.០១៩.១០០ |
| III. អតិរេកថវិកា | 0 | ៤.៣៥២.២៤២.៩៤៤ | +៤.៣៥២.២៤២.៩៤៤ |

មាត្រា ៩.-

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ២២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស.រកម.០២៩៨.០៣, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ អតិរេកនៃថវិការបស់ខេត្ត ក្រុង ដែលមានចំនួនទឹកប្រាក់ ៤.៣៥២.២៤២.៩៤៤ រៀល ត្រូវបានបង់ចូលថវិកាទូទៅរបស់រដ្ឋ ។

# ជំពូកទី ៦
# បទប្បញ្ញត្តិស្តីពី
# និយ័តភាវូបនីយកម្ម
# នៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែម
# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០

មាត្រា ១០.-

ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ៤៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/១២៩៩/១៦ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងមាត្រា ១៦ នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ត្រូវបានយល់ព្រមផ្តល់ឥណទានថវិកាបន្ថែម ដល់ថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដូចខាងក្រោមនេះ ÷

- ចំណាយសំរាប់រដ្ឋសភា រៀបចំសន្និសីទសមាគមសភាអាស៊ីដើម្បីសន្តិភាព ត្រូវបានបុរេប្រទានចំនួន ២.៩៥០ លានរៀល នៅឆ្នាំ ២០០០ ចំនួន ៨០០ លានរៀល និងនៅដើមឆ្នាំ២០០១ ចំនួន ២.១៥០ លានរៀល ។ ចំនួនទឹកប្រាក់

ដែលបានបុរេប្រទានទាំងអស់នេះ នឹងត្រូវធ្វើការទូទាត់ នៅក្នុងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ។

- ចំណាយសង្គ្រោះប្រជាជនរងគ្រោះដោយទឹកជំនន់ និង រាំងស្ងួត ព្រមទាំងចំណាយសំរាប់ស្តារហេដ្ឋារចនាសម្ព័ន្ធឡើងវិញ ក្រោយទឹកជំនន់ ត្រូវបានចេញអនុក្រឹត្យបន្ថែម លេខ ៩២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបន្ថែមឥណទានថវិកាចំនួន ៥៤.០០០ លានរៀល ក្នុងនោះបានធ្វើការទូទាត់ក្នុងឆ្នាំ ២០០០ ចំនួន ២៥.០០០ លានរៀល ហើយចំនួនទឹកប្រាក់ដែលនៅសល់ ២៩. ០០០ លានរៀល នឹងត្រូវធ្វើការទូទាត់នៅក្នុងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ។

- ប្រកាសបន្ថែមលេខ ៥៣២ ប្រក. សហវ.ថហ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការបន្ថែមឥណទានថវិកាចំនួន ៩០០ លានរៀលសំរាប់ខុទ្ទកាល័យនៃក្រសួងព្រះបរមរាជវាំង ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១២.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមករាឆ្នាំ ២០០២

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាក្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

ពរ/ល-០៧-០១-០០០៥

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**គាត ឈន់**

លេខ : ១១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមករា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សោឌី តាន់**

# ព្រះរាជក្រម

នស/រកម/០១០២/០០៥

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ១ស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល-កម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើលក្ខន្តិកៈទីក្រុងរ៉ូមស្តីពី តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យ ប្រជុំពេញអង្គលើក ទី ៦ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើលក្ខន្តិកៈទីក្រុងរ៉ូម
## ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ

**មាត្រា ១.-**

អនុម័តយល់ព្រមលើលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលធ្វើនៅទីក្រុងរ៉ូមប្រទេសអ៊ីតាលី នាថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តលក្ខន្តិកៈទីក្រុងរ៉ូមនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមករា ឆ្នាំ ២០០២

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

ចរណ. ០៧-០១-០០០៦

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ហត្ថលេខា**

**សុខ អាន**

លេខ : ០៩ ច.ល

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

2.02

# ព្រះរាជក្រម

នស/រកម/០១០២/០០៣

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល-កម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៥ របស់អាស៊ានស្តីពីកាតព្វកិច្ចធានារ៉ាប់រងយានយន្ត ដែលរដ្ឋសភាបានអនុម័តកាល ពីថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភា បានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី ៦ នីតិកាលទី ១ ហើយដែលមាន សេចក្តីទាំងស្រុង ដូចតទៅ :

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើពិធីសារទី ៥ របស់អាស៊ាន ស្តីពីកាតព្វកិច្ចធានារ៉ាប់រងយានយន្ត

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារទី ៥ របស់អាស៊ានស្តីពីកាតព្វកិច្ចធានារ៉ាប់រងយានយន្ត ដែលត្រូវបានចុះហត្ថលេខានៅទីក្រុងគូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី នាថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមករា ឆ្នាំ ២០០២

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

នរស-០២.០១.០០០៧ **ហត្ថលេខា**

**ជា ស៊ីម**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ហត្ថលេខា** លេខ: ០៩ ច.ល

**គាត ឈន់**

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

# ព្រះរាជក្រម

នស/រកម/០១០២/០០៤

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលរដ្ឋសភាបានអនុម័តកាល ពីថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ និងដែលព្រឹទ្ធសភាបានអនុម័តលើកចោលពុំពិចារណាលើច្បាប់នេះព្រោះមិនស្របនឹងទម្រង់ច្បាប់ កាលពីថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី ៦ នីតិកាលទី ១ ប៉ុន្តែដោយយោងតាមវាក្យខ័ណ្ឌទី១ និងទី២ នៃមាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាបានពិនិត្យឃើញថា អត្ថបទច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលរដ្ឋសភាបានពិនិត្យរួចហើយៗ ដែលព្រឹទ្ធសភាមិនព្រមផ្តល់យោបល់លើខ្លឹមសារនៃច្បាប់នេះត្រូវចាត់ទុកថាជាបានការ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់
# ស្តីពី
# ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ

**មាត្រា ១.-** គោលបំណង

ច្បាប់នេះមានគោលបំណងកំណត់ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដើម្បីពង្រឹងវិស័យសន្តិសុខសាធារណៈ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-** មធ្យោបាយបង្ហាញភស្តុតាង

១-សាក្សីទាំងអស់ដែលមានឈ្មោះក្នុងសំណុំរឿង រួមទាំងមន្ត្រីនគរបាលយុត្តិធម៌ផង ត្រូវតែបានអនុញ្ញាតនិយាយជូនតុលាការស្តាប់ ។ សាក្សីអាចត្រូវសួរដេញដោលពីសំណាក់ភាគីរដ្ឋប្បវេណី ឬទីប្រឹក្សា ពីសំណាក់ជនជាប់ចោទ ឬទីប្រឹក្សា ហើយនិងពីសំណាក់ព្រះរាជអាជ្ញា ។

២-នៅពេលជំនុំជម្រះ ភស្តុតាងទាំងអស់រួមទាំងកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ផង ត្រូវលើកយកមកជជែកវែកញែក ហើយភស្តុតាងនិងកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ទាំងនោះ មិនអាចចាត់ទុកជាភស្តុតាងដែលមិនអាចប្រានចោលបានទេ ។

៣-បណ្តាពាក្យសារភាពរបស់ជនជាប់ចោទទាំងឡាយ ដែលមិនស៊ីសង្វាក់គ្នាទៅនឹងដើមកំណើតនៃភស្តុតាងទេនោះ ទោះក្នុងករណីណាក៏ដោយ មិនអាចចាត់ទុកជាមូលដ្ឋានសម្រាប់ផ្តន្ទាទោសបានឡើយ ។ ពាក្យសារភាពដែលបានមកអំពីការបង្ខិតបង្ខំតាមបែបណាមួយក៏ដោយ ត្រូវទុកជាមោឃៈ ។ ការសុំទុកជាមោឃៈនេះត្រូវស្នើទៅចៅក្រមដោយទីប្រឹក្សារបស់ជនជាប់ចោទនៅមុនពេលកាត់ក្តី ។

៤-អ្នកការពារជនជាប់ចោទអាចយកសាក្សីខ្លួនមកបង្ហាញតុលាការ ហើយអាចជូនភស្តុតាងខ្លួនទៅតុលាការ ។

៥-សាក្សីទាំងអស់ ទាំងខាងដើមចោទ ទាំងខាងចុងចោទ អាចទទួលការបង្ខំឱ្យបង្ហាញខ្លួនចំពោះមុខតុលាការតាមរយៈដីកានាំខ្លួនរបស់តុលាការ ក្នុងករណីមិនព្រមប្រព្រឹត្តតាមការនាំខ្លួនរបស់តុលាការត្រូវពិន័យជាប្រាក់ពី ៥០.០០០ (ប្រាំម៉ឺន)រៀល ទៅ ៥០០.០០០ (ហាសិបម៉ឺន)រៀល ។

**មាត្រា ៣.-** ឃាតកម្មគិតទុកជាមុន

១-ជនណាដែលសម្លាប់ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀត ក្រោយពីបានគិតទុកជាមុននូវបទឧក្រិដ្ឋរបស់ខ្លួនឬដោយបានរៀបចំការពួនស្ទាក់ ឬដែលបានសម្លាប់ ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀតក្នុងពេលដែលខ្លួនប្រព្រឹត្តចោរកម្ម ឬរំលោភសេពសន្ថវៈ ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតគិតទុកជាមុន ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ ឬអស់មួយជីវិត ។

២-ការគិតទុកជាមុន គឺគម្រោងធ្វើឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលណាម្នាក់ ។

ការពួនស្ទាក់គឺការឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលណាមួយដើម្បីប្រព្រឹត្តអំពើហិង្សាទៅលើបុគ្គលនោះ ។

**មាត្រា ៤.-** អំពើមនុស្សឃាតដោយចេតនា

ជនណាដែលសម្លាប់មនុស្សដោយចេតនាឬប៉ុនប៉ងសម្លាប់ជនណាដោយចេតនាដោយគ្មានស្ថានទម្ងន់ណាដែលមានចែងក្នុងមាត្រា ៣ ដោយបានប្រើ ឬមិនបានប្រើអាវុធក្តី ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១០ ទៅ ១៥ឆ្នាំ ។

ជនណាដែលសម្លាប់មនុស្សដោយចេតនាដោយឃោរឃៅក្នុងកាលៈទេសៈនិងក្នុងទីកន្លែងតែមួយបណ្តាលឱ្យជនណាម្នាក់ឬច្រើននាក់ស្លាប់ ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ ឬអស់មួយជីវិត ។

**មាត្រា ៥.-** បទរំលោភសេពសន្ថវៈ

១-ជនណាក៏ដោយដែលរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភសេពសន្ថវៈលើជនណាម្នាក់ទៀត ទោះបីភេទដូចគ្នាឬមិនដូចគ្នាក៏ដោយ ត្រូវមានទោសពីបទរំលោភសេពសន្ថវៈ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ ។

២-បទរំលោភសេពសន្ថវៈគឺគ្រប់អំពើបញ្ចូលអង្គជាតិឬមធ្យោបាយផ្សេងទៀតដោយឃោរឃៅ ដោយបង្ខំ ឬដោយមិនដឹងខ្លួនជាមុន ។

ប្រសិនបើការរំលោភសេពសន្ថវៈបានប្រព្រឹត្តឡើងដោយការគំរាមកំហែងដោយអាវុធទៅលើស្ត្រីមានផ្ទៃពោះ លើជនមានជំងឺ ឬជនមានសតិវិបល្លាស ឬពិការរាងកាយ ឬលើអនីតិជន អាយុតិចជាង ១៤ឆ្នាំ ធ្វើឡើងដោយមានអ្នកប្រព្រឹត្តម្នាក់ ឬច្រើននាក់ ឬដោយអ្នកសមគំនិត ឬបើការសេពសន្ថវៈត្រូវប្រព្រឹត្តឡើងដោយជនដែលមានអំណាចលើអ្នករងគ្រោះ ទណ្ឌកម្មដែលត្រូវអនុវត្តគឺដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ ។

**មាត្រា ៦.-** អំពើប្លន់

អំពើប្លន់ ជាការបន្លំនិងជាការជំរិតយកទ្រព្យសម្បត្តិអ្នកដទៃ តាមគ្រប់រូបភាព ដោយផ្ទាល់ក្តី ដោយប្រយោលក្តី ក្នុងបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។

ជនណាដែលបានលួច ឬប៉ុនប៉ងលួចជនណាម្នាក់ទៀតដោយមានស្ថានទម្ងន់ទោសណាមួយដូចខាងក្រោម :

-ការលួចធ្វើដោយអំពើហិង្សាមានអាវុធ ឬអត់អាវុធ បណ្តាលឬមិនបណ្តាលឱ្យមានរបួស

-ឬការលួចនោះបានធ្វើឡើងដោយមានគ្នាច្រើន ឬដោយការកាប់គាស់ទម្លុះ ទម្លាយ បំផ្លិចបំផ្លាញ ត្រូវផ្តន្ទាទោសពីបទឧក្រិដ្ឋប្លន់ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ។

-ការលួចធ្វើដោយអំពើហិង្សាមានអាវុធក្តី ឬអត់អាវុធក្តី បណ្តាលឱ្យស្លាប់ម្ចាស់ទ្រព្យ ក្រុមគ្រួសារ ឬអ្នកការពារ អ្នកថែរក្សា ត្រូវមានទោសពីបទឧក្រិដ្ឋឃាតកម្មគិតទុកជាមុន ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ ឬអស់មួយជីវិត ។

**មាត្រា ៧.-** ការចាប់ជំរិតនិងការបង្ខាំងមនុស្សដោយខុសច្បាប់

១-ជនណាដែលគ្មានបញ្ជាពីអាជ្ញាធរតុលាការ បានចាប់ខ្លួន ឬឃុំខ្លួន ឬបង្ខាំងខ្លួន មនុស្សណាក៏ដោយត្រូវមានទោស :

-ដាក់ពន្ធនាគារពី ៣ឆ្នាំ ទៅ ៥ឆ្នាំ បើការបង្ខាំងខ្លួននោះមានរយៈពេលតិចជាង ១ខែ

-ដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ បើការបង្ខាំងខ្លួន ឬការឃុំខ្លួននោះមានរយៈពេលលើសពី ១ខែ ។

២-ជនណាដែលគំរាមតាមគ្រប់រូបភាព តាមមធ្យោបាយណាក៏ដោយ ដើម្បីកំណត់ឱ្យប្រគល់ជាប្រាក់ ឬជាទ្រព្យសម្បត្តិ ក្នុងបំណងដែលខ្លួនចង់បាននោះ ត្រូវមានទោសពីបទឧក្រិដ្ឋជំរិត ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ។

៣-ជនណាដែលប្រព្រឹត្តដោយចេតនា ចាប់ខ្លួនជនណាម្នាក់ ឬច្រើននាក់ យកមកឃុំខ្លួន ឬបង្ខាំងខ្លួន ឬគំរាមធ្វើទារុណកម្មដោយគ្រប់រូបភាពបណ្តាលឱ្យជនណាម្នាក់ស្លាប់ក្តី ឬមិនស្លាប់ក្តី ហើយគំរាមឱ្យតតិយជន ឬជនរងគ្រោះប្រគល់ជាប្រាក់ ឬទ្រព្យសម្បត្តិ ឬអ្វីផ្សេងទៀត ដើម្បីជាថ្នូរទៅតាមបំណងរបស់ខ្លួនត្រូវមានទោសពីបទឧក្រិដ្ឋចាប់ជំរិតនិងបង្ខាំងមនុស្សខុសច្បាប់ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ ឬអស់មួយជីវិត ។

**មាត្រា ៨.-** ការលើកលែងទោស

ចំពោះបទឧក្រិដ្ឋនិងបទឧក្រិដ្ឋតម្រូវឱ្យធ្វើការ ចៅក្រមមិនត្រូវគិតពីស្ថានត្រាប្រណីទោស ឬបន្ធូរបន្ថយទោសក្រោមអប្បបរមា ឬលើកលែងទោសបានឡើយ ។ ចំពោះបទមជ្ឈិមដែលមិនប៉ះពាល់ដល់របៀបរៀបរយសាធារណៈធ្ងន់ធ្ងរទេ អាចត្រូវលើកលែងទោសទាំងមូល ឬមួយផ្នែកបាន ។ ក្នុងករណីនេះ ជនដែលបានប្រព្រឹត្តបទល្មើសមិនត្រូវទទួលរងទណ្ឌកម្មចប់ចុងចប់ដើមទេ ប្រសិនបើខ្លួនមិនបានប្រព្រឹត្តបទល្មើសមួយផ្សេងទៀតដែលមានចែងក្នុងបណ្តាមាត្រាមុនៗក្នុងរយៈពេល ៥ឆ្នាំ ក្រោយពីការកាត់ទោសរបស់ខ្លួន ។

មាត្រា ៩.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

មាត្រា ១០.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមករា ឆ្នាំ ២០០២

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសំបង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

៣រស.០៧.០១.០០០៤

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា**

**ស ខេង យូ ហុកគ្រី**

លេខ : ០៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០០២

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាន់ ឆាន**

២១

# ព្រះរាជក្រម

នស/រកម/០១០២/០០៥

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ២១ក្រ. ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ១៩៩៣

-បានទ្រង់យល់បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល ដែលប្រកាសឱ្យប្រើដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (SNC) ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ១៩៩២

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជានិងរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីវិសោធនកម្មមាត្រា ៣៦ មាត្រា៣៨ មាត្រា៩០ និងមាត្រា៩១ នៃច្បាប់ស្តីពី នីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៤ ខែ វិច្ឆិកាឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី ៦ នីតិកាលទី ១ ហើយដែលមាន សេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់
# ស្ដីពី
# វិសោធនកម្មមាត្រា ៣៦ មាត្រា ៣៨ មាត្រា ៩០ និងមាត្រា ៩១ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ

**មាត្រាតែ ១.-**

មាត្រា ៣៦ មាត្រា ៣៨ មាត្រា ៩០ និងមាត្រា ៩១ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ២១ក្រ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ១៩៩៣ ដោយក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា ត្រូវបានកែប្រែដូចតទៅ :

**មាត្រា ៣៦ ថ្មី.-**

ចាត់ទុកជាមន្ត្រីនគរបាលយុត្តិធម៌ ឬអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌រួមមាន :

១-ព្រះរាជអាជ្ញានិងចៅក្រមស៊ើបអង្កេត "ក្នុងភារកិច្ចតែប៉ុណ្ណោះ"

២-អភិបាល អភិបាលរង ខេត្ត ក្រុង អភិបាល អភិបាលរងស្រុក ខ័ណ្ឌ និង មេឃុំ ចៅសង្កាត់

៣-ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានការិយាល័យ និងប្រធាន អនុប្រធានផ្នែកនៃ :

-នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ

-នាយកដ្ឋាននគរបាលសេដ្ឋកិច្ច

-នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ

-នាយកដ្ឋានប្រឆាំងភេរវកម្ម

-នាយកដ្ឋាននគរបាលព្រំដែន "ចំពោះបទល្មើសឆ្លងដែន"

-នាយកដ្ឋានជនបរទេស

-មន្ទីរប្រឆាំងគ្រឿងញៀន

៤-ស្នងការ ស្នងការរងនគរបាលខេត្ត ក្រុង

៥-ប្រធាន អនុប្រធានការិយាល័យ និងប្រធាន អនុប្រធានផ្នែក ដែលទទួលបន្ទុកការងារព្រហ្មទណ្ឌចំណុះស្នងការនគរបាលខេត្តក្រុងដូចជា :

-ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់

-ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល

-ការិយាល័យនគរបាលសេដ្ឋកិច្ច

-ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ

-ការិយាល័យប្រឆាំងគ្រឿងញៀន

-ការិយាល័យប្រឆាំងភេរវកម្ម

-ការិយាល័យជនបរទេស

៦-អធិការ អធិការរង និងប្រធាន អនុប្រធានផ្នែកព្រហ្មទណ្ឌនៃ អធិការដ្ឋាននគរបាលស្រុក ខ័ណ្ឌ

៧-ប្រធាន អនុប្រធានការិយាល័យនគរបាលចរាចរ និងប្រធាន អនុប្រធានផ្នែកនគរបាលចរាចរ "ចំពោះបទល្មើសចរាចរ"

៨-ប្រធាន អនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាល ឃុំ សង្កាត់ ចំពោះបទល្មើសព្រហ្មទណ្ឌ

៩-មេបញ្ជាការ មេបញ្ជាការរង ព្រមទាំងមន្ត្រីចាប់ពីអនុប្រធានផ្នែកឡើងនៃកងរាជអាវុធហត្ថដែលទទួលការងារព្រហ្មទណ្ឌ "ចំពោះបទល្មើសដែលពាក់ព័ន្ធនឹងកិច្ចការយោធា"

១០-មន្ត្រីនៃក្រសួងឬស្ថាប័នណាដែលច្បាប់បានប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើស

ប្រតិបត្តិការរបស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវមានការដឹកនាំនិងសម្របសម្រួលរបស់ព្រះរាជអាជ្ញាលើនីតិវិធីនិងវិធានស៊ើបអង្កេតដើម្បីធានាការចោទប្រកាន់ឱ្យមានប្រសិទ្ធិភាព ក្រោមការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មានសិទ្ធិប្រគល់ទៅមន្ត្រីនគរបាលយុត្តិធម៌នូវសមត្ថកិច្ចណាមួយដែលមានវិសាលភាពលើដែនដីទាំងមូល ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ចេញ

ប្រកាសណែនាំអំពីរបៀបរបបធ្វើការងារនិងនីតិវិធីខាងផ្លូវរដ្ឋបាលដល់មន្ត្រីនគរបាលយុត្តិធម៌ ។

អភិបាល អភិបាលរង ខេត្ត ក្រុង អភិបាល អភិបាលរងស្រុក ខ័ណ្ឌនិងមេឃុំ ចៅសង្កាត់មានសមត្ថកិច្ចបញ្ជាណែនាំមន្ត្រីនគរបាលយុត្តិធម៌ដែលស្ថិតក្នុងវង្វង់ដែនដីរបស់ខ្លួនគ្រប់គ្រងឱ្យធ្វើប្រតិបត្តិការលើបទល្មើសបាន ហើយប្រតិបត្តិការទាំងឡាយត្រូវមានសហការពីព្រះរាជអាជ្ញា ។

**មាត្រា ៣៨ ថ្មី.-**

មន្ត្រីនគរបាលយុត្តិធម៌

-ទទួលពាក្យបណ្ដឹងទាមទារ បណ្ដឹងបរិហារ ព្រមទាំងរបាយការណ៍នគរបាលយុត្តិធម៌ទាក់ទងបទឧក្រិដ្ឋ បទមជ្ឈិមនិងបទលហុនានា

-ចាត់ចែងប្រមូលភស្តុតាងនានា

-អាចស្នើសុំជំនួយពីកម្លាំងសាធារណៈ

-ធ្វើកំណត់ហេតុ

-អាចទទួលលិខិតបង្គាប់ឱ្យសួរជំនួស

-អាចសម្រេចឃាត់ខ្លួនបានរយៈពេល ៤៨ម៉ោង យ៉ាងយូរ

-ក្នុងករណីរឿងឧក្រិដ្ឋនិងមជ្ឈិមជាក់ស្ដែង អាចសួរយកចម្លើយសាក្សីធ្វើការឆែកឆេរនិងរឹបអូសវត្ថុតាង អាចចាត់តាំងអ្នកជំនាញសម្រេចឃាត់ខ្លួនជនល្មើស "៤៨ម៉ោងយ៉ាងយូរ" ឃាត់ខ្លួនបុគ្គលណាប្រសិនបើមានភស្តុតាង ឬមានការសង្ស័យដែលមានមូលដ្ឋានច្បាស់សមស្របធ្វើការចោទប្រកាន់បាន

-មន្ត្រីនគរបាលយុត្តិធម៌អាចសុំពន្យារពេលឃាត់ខ្លួនជនសង្ស័យបានក្នុងរយៈពេលមិនលើសពី ២៤ម៉ោង ដោយមិនគិតពីថេរវេលាចាំបាច់នៃការដឹកជញ្ជូនក្នុងល័ក្ខខ័ណ្ឌទាំង ៥ ដូចខាងក្រោម :

១-បទឧក្រិដ្ឋធ្ងន់ធ្ងរ

២-មានតម្រុយចង្អុលបង្ហាញច្បាស់ថាបានប្រព្រឹត្តបទល្មើស

៣-ជាវិធានការចាំបាច់ដើម្បីធ្វើឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ

៤-ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅព្រះរាជអាជ្ញា ដើម្បីពិនិត្យផ្ទៀងផ្ទាត់ភាពសមហេតុផល

៥-មានចំណារយល់ព្រមពីព្រះរាជអាជ្ញា ។

ការអនុញ្ញាតឱ្យពន្យារត្រូវដាក់បញ្ចូលក្នុងសំណុំរឿង ។

-ការពន្យារមិនអាចត្រូវយល់ព្រមបានទេ ចំពោះបុគ្គលដែលត្រូវឃាត់ខ្លួននោះមានអាយុតិចជាង ១៨ឆ្នាំ

-អនីតិជនដែលមានអាយុតិចជាង ១៣ឆ្នាំ មិនអាចត្រូវឃាត់ខ្លួនដល់ ៣៦ ម៉ោងឡើយ ។

**មាត្រា ៩០ ថ្មី.-**

កាលបើចៅក្រមស៊ើបអង្កេតឃើញថា ហេតុការណ៍ដែលកើតមានមិនចូលជាបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ ឬក៏គ្មានបន្ទុកគ្រប់គ្រាន់ទៅលើជនល្មើស អំពីបទចោទនោះ ចៅក្រមស៊ើបអង្កេតមានសិទ្ធិសម្រេចចេញដីកាលើកលែងចោទប្រកាន់ ។ តាមគោលការណ៍ ដីការបស់ចៅក្រមស៊ើបអង្កេតត្រូវលើកមូលហេតុនៃការសម្រេចរបស់ខ្លួន ។

ដីកានេះត្រូវជូនទៅព្រះរាជអាជ្ញាភ្លាម ព្រមទាំងសំណុំរឿងដើម្បីឱ្យព្រះរាជអាជ្ញាប្ដឹងតវ៉ាទៅសាលាឧទ្ធរណ៍ក្នុងរយៈពេល ២៤ម៉ោង ។ ប្រសិនបើមានបណ្ដឹងតវ៉ារបស់ព្រះរាជអាជ្ញានោះ ជនជាប់ចោទជាប់ឃុំឃាំង ត្រូវនៅជាប់ឃុំឃាំងដដែល ។ ផ្ទុយទៅវិញ បើគ្មានការតវ៉ារបស់ព្រះរាជអាជ្ញាទេនោះ ចៅក្រមស៊ើបអង្កេតចេញដីកាឱ្យដោះលែងជនជាប់ចោទ ប្រសិនបើជននេះគ្មានត្រូវជាប់ឃុំពីមូលហេតុអ្វីផ្សេងទៀតនោះ។

ដីកាលើកលែងចោទប្រកាន់នេះត្រូវជូនដំណឹងទៅដើមបណ្ដឹង ឬតំណាងដើមបណ្ដឹងមិនលើសពី ៧ថ្ងៃ ។ ក្នុងករណីដែលដើមបណ្ដឹង ឬតំណាងដើមបណ្ដឹងមិនសុខចិត្តទេនោះ អាចធ្វើពាក្យប្ដឹងឧទ្ធរណ៍នៅការិយាល័យក្រឡាបញ្ជីនៃតុលាការនោះចាប់ពីថ្ងៃដែលបានទទួលដំណឹង ។

ក្នុងករណីដែលអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍យល់ព្រមតាមការតវ៉ារបស់ដើមបណ្ដឹង ឬតំណាងដើមបណ្ដឹង អគ្គព្រះរាជអាជ្ញាត្រូវបង្គាប់ឱ្យព្រះរាជអាជ្ញាតុលាការខេត្ត ក្រុង ឬតំណាងអយ្យការផ្សេងទៀតធ្វើការចោទប្រកាន់ ។

ដីកាលើកលែងចោទប្រកាន់ត្រូវជូនដំណឹងទៅដើមបណ្ដឹង ឬតំណាងដើមបណ្ដឹងមិនលើសពី ៧ថ្ងៃ ។ ក្នុងករណីដែលដើមបណ្ដឹង ឬតំណាងដើមបណ្ដឹងមិនសុខចិត្តទេនោះ អាចធ្វើពាក្យតវ៉ាទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដោយផ្ទាល់ ឬតាមរយៈមេធាវីចាប់ពីថ្ងៃបានទទួលដំណឹង ។

មាត្រា ៩១ ថ្មី.-

ប្រសិនបើមានបណ្តឹងវិជ្ជបវរណី ដីកាលើកលែងចោទប្រកាន់ដែលមានការឯកភាពពីព្រះរាជអាជ្ញាផងនោះ ត្រូវជូនដំណឹងដល់ភាគីដើមបណ្តឹងនោះ ។ ក្នុងរយៈពេល ៦០ថ្ងៃ គិតពីថ្ងៃបានទទួលដំណឹង ភាគីដើមបណ្តឹងវិជ្ជបវរណីមានសិទ្ធិប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ ។

ដីកាលើកលែងចោទប្រកាន់នេះ ត្រូវចម្លងជូនទៅមន្ត្រីនគរបាលយុត្តិធម៌មូលដ្ឋាន ។

ប្រសិនបើសាលាឧទ្ធរណ៍បដិសេធដីកាលើកលែងចោទប្រកាន់ ប្រធានសាលាឧទ្ធរណ៍អាចចេញដីកាចាប់ខ្លួនជនជាប់ចោទជាថ្មី ហើយយកមកឃុំខ្លួនបណ្តោះអាសន្នបាន កាលណាជនជាប់ចោទនៅក្រៅឃុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០២

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

នស-០២.០១.០០០៩

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា**

**ស ខេង យូ ហុកគ្រី**

លេខ : ១៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ១៥ ខែមករា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សៅ ឌី តាន់**

នស / រកត / ០១០២/០០១

# ព្រះរាជក្រឹត្យ

## ស្តីពី

## លក្ខន្តិកៈដោយឡែក

## នៃក្របខ័ណ្ឌមន្ត្រីក្រមការការបរទេស

## យើង

**ព្រះបាទសម្តេចព្រះនរោត្តមសីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍ទូទៅ នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី និងដោយមានការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០១

# ត្រាស់បង្គាប់

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីក្រមការការបរទេស ដែលត្រូវបានចាត់ថ្នាក់ ចូលក្នុងប្រភេទ ខ ដូចមានចែងក្នុងមាត្រា៤ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២.-**

មន្ត្រីរាជការ នៃក្របខ័ណ្ឌមន្ត្រីក្រមការការបរទេសនេះ ត្រូវស្ថិតនៅក្រោមឱវាទក្រសួងការបរទេស និងសហប្រតិបត្តិ-ការអន្តរជាតិ ។

**មាត្រា ៣.-**

មន្ត្រីរាជការ នៃក្របខ័ណ្ឌមន្ត្រីក្រមការការបរទេសមានភារកិច្ចជាជំនួយការដល់មន្ត្រីការទូតជាន់ខ្ពស់ ហើយមានឧបនិស្ស័យក្នុងការបំពេញមុខងារក្នុងតំណែង ដឹកនាំអង្គភាពថ្នាក់មធ្យមនៅក្នុងក្រសួង និងនៅស្ថានតំណាងនានា នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ។

## ជំពូកទី ២
## ឋានន្តរស័ក្តិ និងមុខតំណែងនៃក្របខ័ណ្ឌ

**មាត្រា ៤.-**

ក្របខ័ណ្ឌមន្ត្រីក្រមការការបរទេសមាន ៣ ឋានន្តរស័ក្តិ ÷

- នាយក្រមការការបរទេស មាន ៦ ថ្នាក់
- ក្រមការដើមខ្សែការបរទេស មាន ១០ ថ្នាក់
- ក្រមការការបរទេស មាន ១៤ ថ្នាក់

**មាត្រា ៥ .-**

១- នៅរដ្ឋបាលកណ្តាលរបស់ក្រសួង ÷

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិ ក្រមការដើមខ្សែការបរទេស មានឧបនិស្ស័យសំរាប់កាន់មុខតំណែង ជា ÷

- អនុប្រធានការិយាល័យ
- និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិ នាយក្រមការការបរទេស មានឧបនិស្ស័យសំរាប់កាន់មុខតំណែង ជា ÷

- ប្រធានការិយាល័យ
- និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

២- នៅស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ÷

មន្ត្រីរាជការ នៃក្របខ័ណ្ឌមន្ត្រី ក្រមការការបរទេស មានឧបនិស្ស័យសំរាប់កាន់មុខតំណែង ជា ÷

- អនុព័ន្ធ អនុព័ន្ធរងស្ថានទូត ភ្នាក់ងារកុងស៊ុល ។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិ ក្រមការដើមខ្សែការបរទេស អាចកាន់មុខតំណែង ជា ÷

- អនុកុងស៊ុល ។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិ នាយក្រមការការបរទេស អាចកាន់មុខតំណែង ជា ÷

- កុងស៊ុល លេខាធិការទី២ លេខាធិការទី៣ ។

## ជំពូកទី ៣
## ការជ្រើសរើស និងការបណ្តុះបណ្តាលដំបូង

**មាត្រា ៦ .-**

ការជ្រើសរើសបញ្ចូលក្នុងក្របខ័ណ្ឌមន្ត្រីក្រមការការបរទេស ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែងក្នុងចំណោមបេក្ខជន ជាមន្ត្រីរាជការ និង ឬក្នុងចំណោមនិស្សិត ។ ចំនួនតំណែងក្នុងការជ្រើសរើសសំរាប់បេក្ខជនជាមន្ត្រីរាជការ និងសំរាប់បេក្ខជនជានិស្សិត ត្រូវកំណត់ដោយរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ៧ .-**

ការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវធ្វើចំពោះបេក្ខជនដែលមានសញ្ញាប័ត្រយ៉ាងទាប មធ្យមនីតិសាស្ត្រ ឬសញ្ញាប័ត្រដែលមានតម្លៃស្មើ និងមានអាយុយ៉ាងច្រើន ២៥ឆ្នាំ គិតរហូតដល់ថ្ងៃប្រឡង ។ អាយុនេះអាចរំកិលពី ២៥ឆ្នាំ ឡើងដល់ ៣០ឆ្នាំ ស្របតាមមាត្រា១១ នៃច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។

ការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវធ្វើចំពោះមន្ត្រីរាជការទាំងឡាយរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលស្ថិតយ៉ាងទាបបំផុតក្នុងថ្នាក់លេខ១១ នៃក្របខ័ណ្ឌប្រភេទ គ និងមានអាយុច្រើនបំផុត ៤០ឆ្នាំ ។

ចំពោះមន្ត្រីរាជការរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលមានសញ្ញាប័ត្រសមមូលនឹងមធ្យមសិក្សាប័ត្រភាគទី ២ បូកនឹងពីរឆ្នាំសិក្សាក្នុងគ្រឹះស្ថានឧត្តមសិក្សាដែលមានសញ្ញាប័ត្រ អាចប្រឡងចូលក្នុងក្របខ័ណ្ឌនេះបាន ដោយពុំគិតពីល័ក្ខខ័ណ្ឌឋានន្តរស័ក្តិ និងប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុយ៉ាងច្រើនបំផុត ៤០ឆ្នាំ ។

**មាត្រា ៨.-**

បេក្ខជនដែលត្រូវបានជ្រើសរើសតាមរយៈការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ និង ឬក្នុងចំណោមនិស្សិតមានឋានៈជាសិស្សមន្ត្រីក្រមការការបរទេស ហើយត្រូវទទួលការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល ។

## ជំពូកទី ៤
## កម្មសិក្សា និងការតាំងស៊ប់

**មាត្រា ៩ .-**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង សិស្សមន្ត្រីក្រមការការបរទេសត្រូវបានចាត់អោយបំរើការងារនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហើយត្រូវបានតែងតាំងជាមន្ត្រីក្រមការការបរទេសកម្មសិក្សាការី ដោយប្រកាសរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

មន្ត្រីក្រមការការបរទេសកម្មសិក្សាការីទាំងនេះ ត្រូវឆ្លងកាត់កម្មសិក្សាមួយ ដែលមានរយៈពេល ដូចខាងក្រោម ÷

១- ១២ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីនិស្សិត

២ - ៦ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការដែលពុំស្ថិតក្នុងក្របខ័ណ្ឌប្រភេទ គ ។

ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ដែលស្ថិតក្នុងក្របខ័ណ្ឌប្រភេទ គ បំរើការងារក្នុងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ពុំចាំបាច់ឆ្លងកាត់កម្មសិក្សាឡើយ ។

ក្រោយពេលធ្វើកម្មសិក្សាមន្ត្រី ដែលចែងក្នុងចំណុចទី១ និងចំណុចទី ២ ខាងលើ ដែលធ្វើកម្មសិក្សាបានល្អត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិ ក្រមការការបរទេស ។

ក្នុងករណីចាំបាច់ អាចតម្រូវអោយបន្តកម្មសិក្សាបន្ថែមទៀត ដែលមានរយៈពេលអតិបរមាត្រឹម១២ ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី១ និង៦ ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី២ ។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការបំពេញកម្មសិក្សាបន្ថែមនេះត្រូវលុបឈ្មោះចេញ ប្រសិនបើចេញមកពីនិស្សិត ឬមួយត្រូវបញ្ចូលទៅក្នុងក្របខ័ណ្ឌដើមវិញ ប្រសិនបើចេញមកពីមន្ត្រីរាជការ ដោយគិតបញ្ចូលសំរាប់អតីតភាពការងារ ។ ករណីខាងលើនេះ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហើយត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ៣ខែ ក្រោយការបញ្ចប់កម្មសិក្សា ។

មន្ត្រីក្រមការការបរទេស ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ១៤ នៃឋានន្តរស័ក្តិក្រមការការបរទេស ។

មន្ត្រីក្រមការការបរទេស ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការត្រូវបញ្ចូលទៅក្នុងថ្នាក់ ដែលមានសន្ទស្សន៍បៀវត្សខ្ពស់លើ បន្ទាប់ពីសន្ទស្សន៍ចាស់របស់សាមីខ្លួន ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិក្រមការការបរទេស នៃក្របខ័ណ្ឌមន្ត្រីក្រមការការបរទេសត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

## ជំពូកទី ៥
## ការតែងតាំង

**មាត្រា ១០.-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីក្រមការការបរទេសរួចហើយ មន្ត្រីក្រមការការបរទេសទាំងនេះ អាចត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយដូចមានចែងក្នុងមាត្រា៥ ខាងលើ ស្របតាមឋានន្តរស័ក្តិរបស់ខ្លួនតាមបែបបទដូចបានកំណត់ក្នុងមាត្រា២៨ នៃព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៦
## ការតម្លើងថ្នាក់ និងការតម្លើងឋានន្តរស័ក្តិ

**មាត្រា ១១.-**

មន្ត្រី នៃក្របខ័ណ្ឌមន្ត្រីក្រមការការបរទេស ត្រូវបានតម្លើងថ្នាក់ទៅតាមល័ក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា២០ និងមាត្រាបន្តបន្ទាប់ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។

លក្ខណៈសម្បត្តិជាមូលដ្ឋាន ដែលត្រូវពិនិត្យតម្លើងថ្នាក់ ឬឋានន្តរស័ក្តិ មានដូចខាងក្រោម ÷

១- គោរពវិន័យការងារបានត្រឹមត្រូវ

២- មានចំណេះភាសាបរទេស ច្បាស់លាស់

៣-មានស្មារតីទទួលខុសត្រូវ

៤- សម្រេចបានល្អនូវភារកិច្ចដែលប្រគល់អោយ

៥- មានសីលធម៌ល្អ ។

ការតម្លើងថ្នាក់ នៃមន្ត្រីរាជការក្នុងក្របខ័ណ្ឌនេះត្រូវគិតក្នុងសមាមាត្រ បីភាគបួន ក្នុងវេនជ្រើសរើស និងមួយភាគបួនតាមវេនអតីតភាព ហើយត្រូវសំរេចដោយប្រកាសរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ១២ .-**

គោលការណ៍ នៃការតម្លើងឋានន្តរស័ក្តិ ត្រូវតម្លើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬ ក្នុងករណីចាំបាច់ត្រូវតម្លើងទៅក្នុងថ្នាក់ ដែលស្របជាមួយសន្ទស្សន៍បៀវត្សខ្ពស់លើ បន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ការតម្លើងឋានន្តរស័ក្តិ ត្រូវអនុវត្តអោយបានស្របជាមួយចំនួនតំណែងដែលទំនេរនៅក្នុងឋានន្តរស័ក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬតាមរយៈការប្រឡងប្រជែង ឬមួយតាមរយៈការបណ្តុះបណ្តាលរយៈពេលវែងនៅក្នុង ឬក្រៅប្រទេស ។

ការតម្លើងថ្នាក់ និងការតម្លើងឋានន្តរស័ក្តិ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ១៣.-**

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិក្រមការដើមខ្សែការបរទេស គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ១១ នៃឋានន្តរស័ក្តិ ក្រមការការបរទេស ។

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិនាយក្រមការការបរទេស គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ៧ នៃឋានន្តរស័ក្តិ ក្រមការដើមខ្សែការបរទេស ។

ការតម្លើងទៅក្នុងឋានន្តរស័ក្តិមួយខ្ពស់ជាងអាចផ្តល់ឧបនិស្ស័យដល់មន្ត្រីសាមីសំរាប់កាន់មុខតំណែងស្របតាមឋានន្តរស័ក្តិថ្មីនោះ ដូចបានកំណត់ក្នុងមាត្រា៩ នៃលក្ខន្តិកៈដោយឡែកនេះ ។

**មាត្រា ១៤ .-**

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌមន្ត្រីក្រមការការបរទេស និងតម្លៃឯកតា នៃសន្ទស្សន៍ ព្រមទាំងរបបលាភការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូកទី ៧
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៥.-**

អាណត្តិបំរើការងារ នៃមន្ត្រីក្រមការការបរទេសនៅបរទេស ត្រូវកំណត់រយៈពេលបីឆ្នាំ ។ ក្នុងករណីចាំបាច់ អាណត្តិនេះ អាចពន្យារបានមួយឆ្នាំម្តង តែមិនត្រូវលើសពីរយៈពេលបីឆ្នាំឡើយ ។

**មាត្រា ១៦.-**

មន្ត្រីក្រមការការបរទេស បំរើការងាររហូតដល់អាយុ៥៨ឆ្នាំ ទើបចូលនិវត្តន៍ ។ ចំពោះការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ១៧.-**

មន្ត្រីក្រមការការបរទេស ដែលមានសញ្ញាប័ត្របរិញ្ញាប័ត្រ ឬ សញ្ញាប័ត្រសមមូលត្រូវបានតម្លើងថ្នាក់មួយថ្នាក់ជាស្វ័យប្រវត្តិ ។

**មាត្រា ១៨.-**

សញ្ញាស័ក្តិ និងឯកសណ្ឋានសំរាប់មន្ត្រីក្រមការការបរទេស ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**មាត្រា ១៩**

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីក្រមការការបរទេស ត្រូវកសាងចេញពីសមាហរណកម្មនៃមន្ត្រីរាជការទាំងឡាយ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងនៅស្ថានតំណាងនានា នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ២០**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២១**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែមករា ឆ្នាំ ២០០២

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាស់បង្គាប់**

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា**

**ជា ស៊ីម**

៣៧៧-០២-០១-០០០១

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ១៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ ឌាន**

# ព្រះរាជក្រឹត្យ

នស / រកត / ០១០២ /០០៥

## យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មិនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់ប្រកាសអោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និង មាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅ ថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៩៩
- យោងតាមមាត្រា ១១៥ និង មាត្រា ១៥៧ថ្មី នៃរដ្ឋធម្មនុញ្ញ
- យោងតាមសំណើរបស់គណបក្សប្រជាជនកម្ពុជា ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២
- យោងតាមសំណើរបស់ឯកឧត្តម ប្រធានព្រឹទ្ធសភាស្តីទី ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២

## ត្រាស់បង្គាប់

មាត្រា១: តែងតាំងឯកឧត្តម **ជ័យ សាផុន** ជាសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលទី ១ ជំនួសឯកឧត្តម **កែវ សាន** ។

មាត្រា២: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី៧ ខែ មករា ឆ្នាំ ២០០២

ក្នុងព្រះបរមនាម និងតាមព្រះរាជឱង្ការសព្វបន្ទាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

លេខ : ១០ ច.ល

៣៧.០៥-០១-០០០២

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី១០ ខែមករា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ឥស្សាន

នស/រកត/០១០២/០០៦

# ព្រះរាជក្រឹត្យ

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ឯក ជាកិច្ចបច្ឆាមរណៈចំពោះសព ឧត្តមសេនីយ៍ទោ ផា ផនចាន់ អត្តលេខ ០០០១២៦ ទីប្រឹក្សា ក្រសួងការពារជាតិ ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែ មករា ឆ្នាំ ២០០២*

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា**

**ជា ស៊ីម**

ពរល.០៤.០១.០០១១ លេខ : ១៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០១០២/០០៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម សោម ចិន

នូវ

គ្រឿងឥស្សរិយយស

ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០២

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

លេខ : ១៥ ច.ល

៣/ល-០២-០១-០០១២ ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ១៥ ខែមករា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០១០២/០០៤

## យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- យោងតាមសំណើ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានតម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈចំពោះសព វរសេនីយ៍ឯក **សុខ ខាសនា** អត្តលេខ ០០២៣០៣ មេបញ្ជាការរង អង្គរក្សសម្តេចនាយករដ្ឋមន្ត្រី ។

មាត្រា ២: នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវ ព្រះរាជក្រឹត្យនេះ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០២

ភ្នងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

លេខ : ១៦ ច.ល **ហត្ថលេខា**

រដ្ឋីម្បីចម្លងចែក **ជា ស៊ីម**

៣៩៧.០២.០១.០០១៣

រាជធានីភ្នំពេញ . ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០១០២/០០៩

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១ : តែងតាំងឥស្សរជនចំនួន ០៣ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដូចមានរាយនាមខាងក្រោម ÷

១- ឯកឧត្តម សួន រចនា ទទួលបន្ទុកការងារសាធារណការ និងដឹកជញ្ជូន

២- ឯកឧត្តម ម៉ែន រុន ទទួលបន្ទុកការងារកិច្ចការនារី អតីតយុទ្ធជន សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងទំនាក់ទំនងជាមួយខុទ្ទកាល័យឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី

៣- ឯកឧត្តម ស៊ូ ស៊ុម ទទួលបន្ទុកការងារស្រាវជ្រាវ និងចងក្រងឯកសារយុទ្ធសាស្ត្រ

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០២*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

លេខ : ១៧ ច.ល

**ហត្ថលេខា**

**ជា ស៊ីម**

៣រស.០២-០១.០០១៤

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០២

អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ

នស/រកត/០១០២/០២០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានបំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ជូន លោកឧកញ៉ា **ម៉ុង ឫទ្ធី** អគ្គនាយកក្រុមហ៊ុនសំណង់ក្មេងវត្ត ដែលមានគុណបំណាច់ខ្ពស់ និងស្នាដៃល្អ ក្នុងការចូលរួមជាមួយរាជរដ្ឋាភិបាល ស្តារឡើងសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ព្រះពុទ្ធសាសនា និងទ្រទ្រង់កិច្ចការពារជាតិ ។

មាត្រា ២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ៕

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០២*

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

លេខ : ១៨ ច.ល

៣៩ល. ០២. ០១. ០០១៥

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ

នស/រកត/០១០២/០១១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

~~~~~

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក ឈិន រ៉ុនមិញ (CHEN RON-MING) ហៅ តាំង ឡុងមិញ (TANC LONG MING) សញ្ជាតិដើមចិន កើតថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៥៥ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

មាត្រា ២ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០២*
*ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាបង្គាប់*
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា**
**ជា ស៊ីម**

លេខ : ១៩ ច.ល

ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០២
អគ្គលេខាធិការរាជរដ្ឋាភិបាល

៣/ស.០៥.០១.០០១៦
~~~~~

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តសៀមរាប

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ០៣ រូប ដែលបានចំណាយថវិកាផ្ទាល់ខ្លួន ជួយកសាងវត្តសំពៅលូន កុដិតូច ធំ ស្ពាន លូ ទ្វារទឹក ០៣ កន្លែង និង សមិទ្ធផលផ្សេងៗ ទៀត ស្ថិតនៅភូមិសំពៅលូន ឃុំក្រឡាញ់ ស្រុកក្រឡាញ់ ខេត្តសៀមរាប ដូចមានរាយព្រះនាម និង នាមខាងក្រោម ÷

១ - ព្រះតេជគុណ **ពិន ហោ** ព្រះចៅអធិការវត្តសំពៅលូន បច្ច័យ ៧៩.៨២៩ USD

២ - ឯកឧត្តម **គោ ស៊ុំសារឿត** អគ្គនាយកនៃក្រសួងទេសចរណ៍ ថវិកា ៩៣.៩៣៩ USD

៣- លោក **ណៅ ធួក** ប្រធាននាយកដ្ឋានជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ថវិកា ៧៥.៦៧៥ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ៸៶

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ - ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តព្រៃវែង

## សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះតេជគុណ **ព្រះរាជភាវនាវិសុទ្ធិ** ព្រះចៅអធិការវត្តធម្មកាយ និង ជាប្រធានមូលនិធិ នៃព្រះរាជាណាចក្រថៃ ដែលបានជួយកសាង សាលារៀនចំនួន ០៤ ខ្នង មាន ២០បន្ទប់ និង ព្រះវិហារមួយសាងសង់ហើយជាស្ថាពរ ស្ថិតនៅក្នុង ឃុំក្រពៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៤ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យ នស /រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈ ដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១២៥ អនក្រ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីការបង្កើតនាយកដ្ឋាននគរបាលទេសចរណ៍ នៃ ក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១** : ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ត្រី **យុន ឈុន្នី** អត្តលេខ ០០២២ ពីប្រធាននាយកដ្ឋានជនបរទេស ទៅជាប្រធាននាយកដ្ឋាននគរបាលទេសចរណ៍ នៃក្រសួងមហាផ្ទៃ ។

**មាត្រា២** : ត្រូវបានតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ត្រី **មៀច សុផាន់ណា** អត្តលេខ ០២៥២ ពីអនុប្រធាននាយកដ្ឋានជនបរទេស ទៅជាប្រធាននាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ ។

**មាត្រា៣** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង - ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល :*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ-កាលប្បវត្តិ* ✓

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១៥ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

* * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

### សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការចំនួន ៦៣ រូប ដែលមានស្នាដៃល្អក្នុងសកម្មភាពការងារ លើវិស័យអភិវឌ្ឍន៍ជនបទ ដូចមានរាយនាមខាងក្រោមនេះ ÷

**ក_មេដាយប្រាក់ការងារ :**

១-លោក **ប្រាក់ ឡេង** នាយកខុទ្ទកាល័យ

២-លោក **សំ នី** ប្រធានការដ្ឋាន វិស្វករពិនិត្យបច្ចេកទេសប្រចាំការដ្ឋាន ខេត្តកំពត

៣-លោក **ឡុង ម៉ុនឡុង** ប្រធានការដ្ឋាន វិស្វករពិនិត្យបច្ចេកទេសប្រចាំការដ្ឋាន ខេត្តស្វាយរៀង

៤-លោក **សេង ជាសុខ** ប្រធានការដ្ឋាន វិស្វករពិនិត្យបច្ចេកទេសប្រចាំការដ្ឋាន ខេត្តកំពង់ធំ

៥-លោក **ហេង ឈួង** ប្រធានការដ្ឋាន វិស្វករពិនិត្យបច្ចេកទេសប្រចាំការដ្ឋាន ខេត្តកណ្តាល

៦-លោក **យូ ហ៊ួត** ប្រធានការដ្ឋាន វិស្វករពិនិត្យបច្ចេកទេសប្រចាំការដ្ឋាន ខេត្តព្រៃវែង

៧-លោក **អ៊ឹម ចាន់ថា** វិស្វករប្រចាំការដ្ឋាន ខេត្តព្រៃវែង

៨-លោក **ឡាំ សុវណ្ណដារ៉ា** វិស្វករប្រចាំការដ្ឋាន ខេត្តកំពត

៩-លោក ជួន ជាតិន វិស្វករប្រចាំការដ្ឋាន ខេត្តកំពត
១០-លោក កែ ម៉ុនធឿន ប្រធានការដ្ឋាន វិស្វករពិនិត្យបច្ចេកទេសប្រចាំការដ្ឋាន ខេត្តកំពង់ចាម
១១-លោក តាន់ វាសនា អ្នកបច្ចេកទេសប្រចាំការដ្ឋាន ខេត្តកំពង់ធំ
១២-លោក ហាន សុធី ប្រធានការដ្ឋាន វិស្វករពិនិត្យបច្ចេកទេសប្រចាំការដ្ឋាន ខេត្តតាកែវ
១៣-លោក វ៉ាន់ សុផាត ប្រធានការដ្ឋាន វិស្វករពិនិត្យបច្ចេកទេសប្រចាំការដ្ឋាន ខេត្តកំពង់ឆ្នាំង
១៤-លោក គីម ផុន អ្នកបច្ចេកទេសប្រចាំការដ្ឋាន ខេត្តកំពង់ចាម
១៥-លោក អ៊ូម ចាន់តត្ថិ វិស្វករប្រចាំការដ្ឋាន ខេត្តកំពង់ចាម
១៦-លោក ម៉ុង ហុងគ្រី វិស្វករប្រចាំការដ្ឋានផ្នែកសំណង់ ខេត្តកំពង់ចាម
១៧-លោក ឆេង សុវត្ថ វិស្វករជំនួយការគំរោង ( នាយកដ្ឋានផែនការ និង ទំនាក់ទំនងសាធារណៈ )
១៨-លោក រស់ សុវត្ថា វិស្វករប្រចាំការដ្ឋាន ខេត្តព្រៃវែង

ខ_មេដាយសំរិទ្ធការងារ :

១-លោក ពេជ្រ សំអាង មន្ត្រីខុទ្ទកាល័យ
២-លោក កែ មុនី មន្ត្រីអគ្គនាយកដ្ឋានបច្ចេកទេស
៣-លោក គ្រាក់ ធឿន អនុប្រធានមន្ទីរ ខេត្តមណ្ឌលគិរី
៤-លោក ឈុន ស៊ីវីថា មន្ត្រីរដ្ឋបាលនាយកដ្ឋានផែនការ និង ទំនាក់ទំនងសាធារណៈ
៥-លោក ទ្រី ឡាយ មន្ត្រីនាយកដ្ឋានបណ្តុះបណ្តាល និង ស្រាវជ្រាវ
៦-លោក វ៉ាន់ ផុល មន្ត្រីនាយកដ្ឋានសេដ្ឋកិច្ចជនបទ
៧-លោក ស៊ុន ឈាង មន្ត្រីនាយកដ្ឋានផ្គត់ផ្គង់-ហិរញ្ញវត្ថុ
៨-លោក ប៉ែន សុខុម មន្ត្រីនាយកដ្ឋានផ្គត់ផ្គង់-ហិរញ្ញវត្ថុ
៩-លោក ជៃ សំអាត មន្ត្រីនាយកដ្ឋានរដ្ឋបាល-បុគ្គលិក
១០-លោក សួស បូរិន្ទសក្តិ មន្ត្រីនាយកដ្ឋានរដ្ឋបាល-បុគ្គលិក
១១-លោកស្រី ឈឹម បូរ៉ា មន្ត្រីនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ
១២-លោក សុផាត ចន្ទ្រាវុធ មន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍
១៣-លោក ផាវ ម៉េងហុង ប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម
១៤-លោក ឡៃ ចិន្តា ប្រធានការិយាល័យទឹកស្អាត មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម
១៥-អ្នកស្រី អ៊ុន ណាស៊ី ប្រធានការិយាល័យរដ្ឋបាល មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ឆ្នាំង
១៦-អ្នកស្រី គួច សាវី ប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តបាត់ដំបង

| | | |
|---|---|---|
| ១៧-លោក | ឡូញ ឡូញ | ប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុមន្ទីរអភិវឌ្ឍន៍ជនបទខេត្តបន្ទាយមានជ័យ |
| ១៨-លោក | ស៊ឺន សុខគូ | ប្រធានការិយាល័យសុខភាពជនបទ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តបន្ទាយមានជ័យ |
| ១៩-លោក | នី ហុង | ប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តពោធិសាត់ |
| ២០-លោក | ជួន ហ៊ន | ប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ |
| ២១-លោក | យុត គឹមសាន | អនុប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ |
| ២២-លោក | នេព នេទោ | អនុប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុមន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប |
| ២៣-លោក | ហ៊ុន វណ្ណា | មន្ត្រីរដ្ឋបាល-ហិរញ្ញវត្ថុ ខេត្តកណ្តាល |
| ២៤-លោក | ម៉ែន សុខ | ប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពត |
| ២៥-អ្នកស្រី | ហ៊ុន សោភី | មន្ត្រីការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពត |
| ២៦-លោក | អេង គីរុន | ប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តព្រៃវែង |
| ២៧-លោក | ហុក បូនី | ប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តស្វាយរៀង |
| ២៨-អ្នកស្រី | អន សាមល | មន្ត្រីការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តស្វាយរៀង |
| ២៩-អ្នកស្រី | ឡេង ស៊ាងហ៊ី | ប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ |
| ២៧-លោក | ហុក បូនី | ប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តស្វាយរៀង |
| ២៨-អ្នកស្រី | អន សាមល | មន្ត្រីការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តស្វាយរៀង |
| ២៩-អ្នកស្រី | ឡេង ស៊ាងហ៊ី | ប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍ មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តក្រចេះ |
| ៣០-លោក | សម្បត្តិ មុនី | ប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តស្ទឹងត្រែង |
| ៣១-អ្នកស្រី | ធា ប៊ុនធឿន | ប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តមណ្ឌលគីរី |
| ៣២-លោក | ស្រេង ស្រៀង | ប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរអភិវឌ្ឍន៍ជនបទ ក្រុងប៉ៃលិន |
| ៣៣-លោក | ងួន សុផល | ប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តព្រះវិហារ |
| ៣៤-លោក | កែវ រឿន | ប្រធានការិយាល័យទឹកស្អាត មន្ទីរអភិវឌ្ឍន៍ជនបទ ក្រុងព្រះសីហនុ |
| ៣៥-លោក | ជួង វិរុទ្ធ | ប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរអភិវឌ្ឍន៍ជនបទ ក្រុងកែប |
| ៣៦-លោក | អៀម សុខ | ប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរអភិវឌ្ឍន៍ជនបទ រាជធានីភ្នំពេញ |
| ៣៧-លោក | សោម ដា | ប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកោះកុង |
| ៣៨-លោក | ហាង ស៊ីផុល | អនុប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ |
| ៣៩-កញ្ញា | ឌុក សារិន | ប្រធានការិយាល័យអភិវឌ្ឍន៍ស្រុកត្រាំកក់ មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តតាកែវ |
| ៤០-លោក | អ៊ឹម សម្បត្តិ | ប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ស្ពឺ |

៤១-លោកស្រី **ឌុច គីមពៅ** លេខា ឯកឧត្តម រដ្ឋលេខាធិការ

៤២-លោកស្រី **គង់ សុខា** លេខា ឯកឧត្តម អនុរដ្ឋលេខាធិការ

៤៣-កញ្ញា **ឃឹម ចិន្តា** លេខា ឯកឧត្តម អនុរដ្ឋលេខាធិការ

៤៤-លោកស្រី **ឃុន សុគន្ធាវត្តី** លេខា ឯកឧត្តម អនុរដ្ឋលេខាធិការ

៤៥-លោកស្រី **សួន នី** មន្ត្រីខុទ្ទល័យ

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ......១៦......អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០២ រូប ដែលបានជួយសាងសង់អគារសិក្សា នៅខេត្តព្រៃវែង និង ក្រុងព្រះសីហនុ ដូចមានរាយនាមខាងក្រោមនេះ ÷

១-អង្គការ **JHP** ( Japan Team of Human Power ) ប្រទេសជប៉ុនជួយកសាងអគារសិក្សា ០១ ខ្នង មាន ០៥ បន្ទប់ នៅសាលាបឋមសិក្សាព្រៃគី ឃុំស្មោងខាងត្បូង ស្រុកកំចាយមារ ខេត្តព្រៃវែង អស់ថវិកា ចំនួន ២៩.៦៨២ ដុល្លារអាមេរិក ។

២-លោកស្រី **អូសាណៃ មិអ៊ិកុ** ( OSANAI MIEKO ) ប្រធានអង្គការ JHP ជប៉ុន ជួយកសាងអគារ ០១ ខ្នង សំរាប់ហាត់ភ្លេង នៅសាលាគរុកោសល្យ ក្រុងព្រះសីហនុ អស់ថវិកាចំនួន ២៣.០០០ ដុល្លារអាមេរិក

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៣/អនក្រ.កត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
*******
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនដល់អស់លោក មេឃុំ ក្នុងខេត្តកំពង់ឆ្នាំង ចំនួន ៦៩រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចកន្លងមក ដូចមានរាយនាមខាងក្រោម:

១- លោក **លឹម ខុង** មេឃុំ **ផ្សារឆ្នាំង** ស្រុក **កំពង់ឆ្នាំង**
២- លោក **ហម ហាន** មេឃុំ **កំពង់ឆ្នាំង** ស្រុក **កំពង់ឆ្នាំង**
៣- លោក **ប៉ែន ស៊ីថា** មេឃុំ **ប្អេរ** ស្រុក **កំពង់ឆ្នាំង**
៤- លោក **ឈួរ ជន** មេឃុំ **ខ្សាម** ស្រុក **កំពង់ឆ្នាំង**
៥- លោក **សាន អឿន** មេឃុំ **ពពេល** ស្រុក **បរិបូណ៌**
៦- លោក **ចាន់ ហឿន** មេឃុំ **ឆ្នុកទ្រូ** ស្រុក **បរិបូណ៌**

| | | | | | |
|---|---|---|---|---|---|
| ៧- | លោក ហែម ផន | មេឃុំ | ផ្សារ | ស្រុក | បរិបូណ៌ |
| ៨- | លោក ជឹម ប៊ុង | មេឃុំ | ពេជចង្វារ | ស្រុក | បរិបូណ៌ |
| ៩- | លោក សាយ ព្រែក | មេឃុំ | ចក | ស្រុក | បរិបូណ៌ |
| ១០- | លោក អ៊ុក លន | មេឃុំ | កំពង់ព្រះគគី | ស្រុក | បរិបូណ៌ |
| ១១- | លោក សាំង ខាត់ | មេឃុំ | ត្រពាំងចាន់ | ស្រុក | បរិបូណ៌ |
| ១២- | លោក អៀន ឆន់ | មេឃុំ | ពន្លៃ | ស្រុក | បរិបូណ៌ |
| ១៣- | លោក ឡាញ់ ជិន | មេឃុំ | មេលំ | ស្រុក | បរិបូណ៌ |
| ១៤- | លោក ចាន់ អាន | មេឃុំ | ខុនរ៉ង | ស្រុក | បរិបូណ៌ |
| ១៥- | លោក ជឹម សុខេង | មេឃុំ | អញ្ចាញរូង | ស្រុក | បរិបូណ៌ |
| ១៦- | លោក អៀង គី | មេឃុំ | ត្រងិល | ស្រុក | កំពង់លែង |
| ១៧- | លោក នៅ ស៊ីម | មេឃុំ | ប្រឡាយមាស | ស្រុក | កំពង់លែង |
| ១៨- | លោក អេង ហ៊ាន | មេឃុំ | ស្វាយរំពារ | ស្រុក | កំពង់លែង |
| ១៩- | លោក អឿ សេងហុង | មេឃុំ | ពោធិ | ស្រុក | កំពង់លែង |
| ២០- | លោក ជិន ចុន | មេឃុំ | ជារ | ស្រុក | កំពង់លែង |
| ២១- | លោក ហង់ ស៊ីថា | មេឃុំ | កំពង់ហៅ | ស្រុក | កំពង់លែង |
| ២២- | លោក ឡេង សុងហេង | មេឃុំ | ផ្លូវទូក | ស្រុក | កំពង់លែង |
| ២៣- | លោក ខៀវ វឿង | មេឃុំ | សំរោងសែន | ស្រុក | កំពង់លែង |
| ២៤- | លោក ស្រី ឡេង | មេឃុំ | ច្រណូក | ស្រុក | កំពង់លែង |
| ២៥- | លោក ឃុន ឃី | មេឃុំ | ប្រស្និប | ស្រុក | រលាប្អៀរ |
| ២៦- | លោក ថោង ស៊ីម | មេឃុំ | ក្រាំងលាវ | ស្រុក | រលាប្អៀរ |
| ២៧- | លោក ទ៊ា អ៊ុម | មេឃុំ | គោកបន្ទាយ | ស្រុក | រលាប្អៀរ |
| ២៨- | លោក ស៊ីវ ហ៊ីន | មេឃុំ | ពង្រ | ស្រុក | រលាប្អៀរ |
| ២៩- | លោក សំ ចឿន | មេឃុំ | អណ្តូងស្នាយ | ស្រុក | រលាប្អៀរ |
| ៣០- | លោក ទេព ហម | មេឃុំ | រលាប្អៀរ | ស្រុក | រលាប្អៀរ |
| ៣១- | លោក គោគ ឈួន | មេឃុំ | ព្រៃមូល | ស្រុក | រលាប្អៀរ |
| ៣២- | លោក រិត ហាន | មេឃុំ | ជ្រៃបាក់ | ស្រុក | រលាប្អៀរ |
| ៣៣- | លោក នូ ខៀន | មេឃុំ | ស្រែថ្មី | ស្រុក | រលាប្អៀរ |
| ៣៤- | លោក ឆន់ អ៊ុម | មេឃុំ | ទឹកហូត | ស្រុក | រលាប្អៀរ |
| ៣៥- | លោក សោ សន | មេឃុំ | ជើងគ្រាវ | ស្រុក | រលាប្អៀរ |

៣៦- លោក ទូ សាមុត មេឃុំ បន្ទាយព្រាល ស្រុក រលាប្អៀរ
៣៧- លោក ជា ឈឿង មេឃុំ ស្វាយជ្រុំ ស្រុក រលាប្អៀរ
៣៨- លោក កែវ វ៉ែង មេឃុំ ពានី ស្រុក កំពង់ត្រឡាច
៣៩- លោក ដូ ខែម មេឃុំ ថ្មឥដ្ឋ ស្រុក កំពង់ត្រឡាច
៤០- លោក ឡោ លាស់ មេឃុំ ឈូកស ស្រុក កំពង់ត្រឡាច
៤១- លោក នួន ទើត មេឃុំ លង្វែក ស្រុក កំពង់ត្រឡាច
៤២- លោក ឯក ជិន មេឃុំ អូឫស្សី ស្រុក កំពង់ត្រឡាច
៤៣- លោក ហួត វ៉ាន់ហាន មេឃុំ តាជេស ស្រុក កំពង់ត្រឡាច
៤៤- លោក សុខ សឿ មេឃុំ សែប ស្រុក កំពង់ត្រឡាច
៤៥- លោក ពៅ ខន មេឃុំ ជ្រែស ស្រុក កំពង់ត្រឡាច
៤៦- លោក ខៀវ ដូ មេឃុំ កំពង់ត្រឡាច ស្រុក កំពង់ត្រឡាច
៤៧- លោក សំ ម៉ី មេឃុំ អំពិលទឹក ស្រុក កំពង់ត្រឡាច
៤៨- លោក សួន សឿង មេឃុំ ស្វាយ ស្រុក សាមគ្គីមានជ័យ
៤៩- លោក អ៊ុក ទួន មេឃុំ ស្វាយជុក ស្រុក សាមគ្គីមានជ័យ
៥០- លោក ឱរ កុំ មេឃុំ ខ្លាឆ្មារ ស្រុក សាមគ្គីមានជ័យ
៥១- លោក ម៉ី សារីម មេឃុំ ឆ្លកទៀន ស្រុក សាមគ្គីមានជ័យ
៥២- លោក ឃ្លាំង វី មេឃុំ ក្រាំងល្វា ស្រុក សាមគ្គីមានជ័យ
៥៣- លោក ឈឹម សារិទ្ធ មេឃុំ សេដ្ឋី ស្រុក សាមគ្គីមានជ័យ
៥៤- លោក សួន ថុល មេឃុំ ពាម ស្រុក សាមគ្គីមានជ័យ
៥៥- លោក ស៊ូ សុត មេឃុំ ឈានឡើង ស្រុក សាមគ្គីមានជ័យ
៥៦- លោក ជា ម៉ាន មេឃុំ ត្បែងខ្ពស់ ស្រុក សាមគ្គីមានជ័យ
៥៧- លោក ហង្ស ជឿន មេឃុំ កំពង់អុស ស្រុក ជលគីរី
៥៨- លោក ផង់ អ៊ិត មេឃុំ ជលសារ ស្រុក ជលគីរី
៥៩- លោក អឿង ជា មេឃុំ កោះថ្កូវ ស្រុក ជលគីរី
៦០- លោក កែ ម៉េត មេឃុំ ពាមឆ្កោក ស្រុក ជលគីរី
